# ព្រឹទ្ធសភា

# *SENATE MAGAZINE*

## ទស្សនាវដ្តីប្រចាំខែកក្កដា





លេខ ២៧៣ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 273 Volume 23 Before Christ 2567 Common Era 2023

# មាតិកា


## សកម្មភាពថ្នាក់ដឹកនាំ




-ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញដង្ហែព្រះមហាក្សត្រក្នុងព្រះរាជពិធីបុណ្យទិវា នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ........ ១
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៨ ........ ៣
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីភាពបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧ ........ ៥
- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េចូលជួបសម្តែងការគួរសម ........ ៨
- ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីភាព ក្នុងពិធីបើកសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្តីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ ........ ១០
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ១៣

## សកម្មភាពគណៈកម្មការ



- គណៈកម្មការទី១០ ព្រឹទ្ធសភា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ........ ១៤
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាល អាជ្ញាធរឃុំចំនួន៤ ក្នុងស្រុកក្រូចឆ្មារ ........ ១៦
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ១៨
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ........ ២២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៣៦
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៣៨
- ការងារទទួលពាក្យបណ្តឹង ........ ៣៨

## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងឆមាសទី១ ព្រមទាំងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២៣ ........ ៣៩
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមហ៊ុន Huawei រៀបចំសិក្ខាសាលាស្តីពី ការពន្លឿនហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការបង្កើតតម្លៃថ្មីសម្រាប់សេដ្ឋកិច្ចឌីជីថល ..... ៤០
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៤២



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លឹម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម គឹម ពិសិដ្ឋ
ឯកឧត្តម ជួន ណា
លោក ជួន សុខធី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា
លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅការិយាល័យបោះឆ្នោតលេខ០២៣១ មណ្ឌលវត្តកោះ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញដង្ហែព្រះមហាក្សត្រក្នុង ព្រះរាជពិធីរុក្ខទិវា នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង





*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញដង្ហែព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីរុក្ខទិវា នៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំង*

នាព្រឹកថ្ងៃអាទិត្យ ទី៩ ខែកក្កដា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្ដម កិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមដង្ហែព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះរាជពិធីរុក្ខទិវា "នៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក" ស្ថិតក្នុងភូមិអូរកាខុប ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

ព្រះរាជពិធីរុក្ខទិវា ៩ កក្កដា ២០២៣ នេះ ប្រារព្ធឡើងលើផ្ទៃដី១០ហិកតា និងត្រូវដាំកូនធ្នង់ ប្រេស គីនីន ក្រញូង ស្ដែ



*ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា យាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ បំផុតក្នុងព្រះរាជពិធីរុក្ខទិវា*

និងក្រោក សរុបជាង១ម៉ឺន៣ពាន់ដើម។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ “រុក្ខទិវា” ៩កក្កដា ឆ្នាំ២០២៣ រៀបចំឡើងក្នុងគោលបំណងដាំស្ដារព្រៃឈើឡើងវិញ អភិវឌ្ឍជីវៈចម្រុះ រួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងទ្រទ្រង់សកម្មភាពផ្សេងៗជាច្រើនទៀត សម្រាប់ផលប្រយោជន៍របស់ប្រជាសហគមន៍។ ទិវានេះ ក៏ជាទិវាមួយដែលត្រូវបានប្រារព្ធធ្វើឡើង ដើម្បីជំរុញចលនាដាំដុះឡើងវិញនូវកូនឈើ និងបំផុសស្មារតីស្រឡាញ់ព្រៃឈើ ធនធានធម្មជាតិក្នុងសង្គម ក្នុងការចូលរួមថែរក្សា ការពារ និងបញ្ចប់ការកាប់បំផ្លាញព្រៃឈើ និងធនធានធម្មជាតិផងដែរ។

គិតត្រឹមឆ្នាំ២០២២ រដ្ឋបាលព្រៃឈើបានបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្ដារព្រៃឈើជាច្រើនដែលមានទំហំសរុបជាង៥០ម៉ឺនហិកតា បានថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូត៍បង្ហាញកសិ-រុក្ខកម្មចំនួន៨២២ហិកតា និងបាន



*ទិដ្ឋភាពក្នុងព្រះរាជពិធីរុក្ខទិវា*

ពង្រឹងប្រសិទ្ធភាព នៃការគ្រប់គ្រងព្រៃបម្រុងទុក ដូចជាការបង្កើតតំបន់សូនភូតគាម និងការបោះបង្គោលព្រំប្រទល់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលការងារទាំងអស់នេះពិតជាបានឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់អនុវិស័យព្រៃឈើ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)





# សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៨



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា* *សម្តេចវិបុលសេនាភក្តី សាយ ឈុំ* *ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

របៀបវារៈចំនួន៨ ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាលើកយកមកពិនិត្យ សម្រេច នាព្រឹកថ្ងៃពុធ ទី២៨ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។ របៀបវារៈទាំង៨នោះ រួមមាន៖

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ខ្មែរ អេឡិកទ្រីខល ផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងឫស្សីជ្រំកណ្តាល អានុភាព៧០មេហ្គាវ៉ាត់ ផ្គួបគ្នាជាមួយនឹងគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុត អនុភាព១០០មេហ្គាវ៉ាត់ ខេត្តកោះកុង ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការ





*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ឡាក់យី សូឡាផៅវ័រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះ-អាទិត្យ អានុភាព៨០មេហ្គាវ៉ាត់ ខេត្តព្រៃវែង ទៅក្នុងរបៀប-វារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេចេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តពោធិ៍សាត់ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេចេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០មេហ្គាវ៉ាត់ ខេត្តស្វាយរៀង ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៦-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្នេចេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០មេហ្គាវ៉ាត់ ខេត្តកំពង់ឆ្នាំង ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៧-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស្ទឹង មេទឹក ហាយដ្រូផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងមេទឹក អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

៨-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការ-អចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃព្រហស្បតិ៍ ទី២៩ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ទាំង៧ខាងលើ៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)



ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីភាព បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ*
*ដឹកនាំការបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៩រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៧ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។**

របៀបវារៈទី១នេះ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ថា សេចក្តីព្រាងច្បាប់នេះ តាក់តែងឡើងមានគោលបំណងដើម្បីលើកស្ទួយគុណតម្លៃ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដើម្បីពង្រឹង និងលើកកម្ពស់ដំណើរការប្រជាធិបតេយ្យនៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសដើម្បីឱ្យអនាគតអ្នកដឹកនាំនយោបាយដែលមានបំណងចង់ឈរឈ្មោះឱ្យគេបោះឆ្នោតតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ទាំងនៅថ្នាក់ជាតិ និងទាំងនៅថ្នាក់ក្រោមជាតិ មានការទទួលខុសត្រូវក្នុងនាមជាពលរដ្ឋល្អចំពោះជាតិ និងប្រជាជន ដោយចាប់ផ្តើមពីការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវសិទ្ធិបោះឆ្នោត ដែលជាករណីយកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបចំពោះប្រទេសជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងដំណើរការបោះឆ្នោត



*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា ចូលរួមក្នុងការបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤*



ឯកឧត្តម អ៊ុក ប៊ុនឈឿន ឡើងអានរបាយការណ៍

ជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពង្រឹងដំណើរការ នៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងពង្រឹងនីតិរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។

បន្ទាប់ពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



ឯកឧត្តម កើត រិទ្ធ អញ្ជើញការពារសេចក្តីព្រាងច្បាប់

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនខ្មែរអេឡិកទ្រីខល ផៅវើរ សម្រាប់អនុវត្តគម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រំកណ្តាល អានុភាព៧០មេហ្កាវ៉ាត់ ផ្គួបគ្នាជាមួយនឹងគម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងវាលថ្មកំបុតអានុភាព ១០០មេហ្កាវ៉ាត់ ខេត្តកោះកុង។

របៀបវារៈទី៣៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនឡាក់ឃី សូឡាផៅវើរ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៨០មេហ្កាវ៉ាត់ ខេត្តព្រៃវែង។

របៀបវារៈទី៤៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០មេហ្កាវ៉ាត់ ខេត្តពោធិ៍សាត់។

របៀបវារៈទី៥៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌីសម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០មេហ្កាវ៉ាត់ ខេត្តស្វាយរៀង។

របៀបវារៈទី៦៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌីសម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៦០មេហ្កាវ៉ាត់ ខេត្តកំពង់ឆ្នាំង។

របៀបវារៈទី៧៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្ទឹងមេទឹក ហាយដ្រូផៅវើរ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងមេទឹក អានុភាព១៥០មេហ្កាវ៉ាត់ ខេត្តកោះកុង។

សេចក្តីព្រាងច្បាប់ក្នុងរបៀបវារៈទី២ ទី៣ ទី៤ ទី៥



ឯកឧត្តម ជា ជេដ្ឋ ឡើងអានរបាយការណ៍

ទី៦និងទី៧ខាងលើ ត្រូវបានឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ជេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ថា សេចក្ដីព្រាងច្បាប់ទាំង៦នេះ មានសារៈសំខាន់ក្នុងការជួយទ្រទ្រង់ដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចឱ្យកាន់តែមានភាពរីកចម្រើនជឿនលឿន ធានាឱ្យមានសមធម៌សង្គម និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងថែមទៀត តាមរយៈការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចុះតម្លៃអគ្គិសនី និងការផ្គត់ផ្គង់អគ្គិសនីឱ្យប្រជាពលរដ្ឋគ្រប់ភូមិមានអគ្គិសនីប្រើប្រាស់។

សេចក្ដីព្រាងច្បាប់ទី២ដល់ទី៧ ត្រូវបានទទួលស្គាល់ជាទូទៅថា ជាថាមពលស្អាតពុំមានផលប៉ះពាល់អ្វីធំដុំដល់បរិស្ថានធម្មជាតិ និងសង្គមឡើយ ទាំងក្នុងដំណាក់កាលកំពុងសាងសង់ ក៏ដូចជាក្នុងដំណាក់កាលប្រតិបត្តិការ។

ចំណែកឯប្រយោជន៍ទទួលបានពីគម្រោងទាំងអស់នេះ មានទំហំធំធេង ដែលអាចចូលរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ សង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាពិសេសដើម្បីធានាសុវត្ថិភាព និងសន្តិសុខ នៃការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់។

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពលបានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



ឯកឧត្តម ស៊ុយ សែម អញ្ជើញការពារសេចក្ដីព្រាងច្បាប់

សម្រាប់សេចក្ដីព្រាងច្បាប់ទាំង៦ចុងក្រោយ អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់នីមួយៗទាំងមូល ដោយឥតកែប្រែ ចំនួន៥៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)



ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្ដីព្រាងច្បាប់

# សម្ដេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិត សកល នៃសាធារណរដ្ឋកូរ៉េចូលជួបសម្ដែងការគួរសម



*លោក Kim Jung Nam និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង៩:០០ នាទី នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាត ឱ្យលោក Kim Jung Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះ ជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្ដែងការគួរសម។

សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការស្វាគមន៍ ចំពោះលោកប្រធានមូលនិធិ និងគណៈប្រតិភូ ដែលបាន អញ្ជើញបំពេញបេសកកម្មមនុស្សធម៌ជាលើកទី២ នៅ ព្រះរាជាណាចក្រកម្ពុជា។ បេសកកម្មការងារមនុស្សធម៌នា ឱកាសនេះនឹងទទួលបានលទ្ធផលកាន់តែល្អប្រសើរ ព្រមទាំងនាំមកនូវការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនយើងទាំងពីរឱ្យកាន់ តែល្អជាងមុនទៀត ដើម្បីគុណប្រយោជន៍សម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-កូរ៉េ ដែលត្រូវបានពង្រឹងពង្រីកជាប្រចាំ លើ វិស័យនយោបាយ ការបរទេស សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ សិល្បៈ វប្បធម៌ អប់រំ កីឡា ការផ្លាស់ប្ដូរប្រជាជន និងប្រជាជន ព្រមទាំងមានចំណងមេត្រីភាពរវាងខេត្តក្រុង នៃប្រទេសទាំងពីរ។

ក្នុងនាមគណៈប្រតិភូ លោក Kim Jung Nam បានថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលដ៏មានតម្លៃទទួលជួបគណៈប្រតិភូ។ លោកប្រធានមូលនិធិបានជម្រាបជូនសម្ដេចថា តាមរយៈ ការចុះអនុស្សរណៈយោគយល់គ្នារវាងព្រឹទ្ធសភាកម្ពុជាជា មួយនឹងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ កាលពីខែកញ្ញា ឆ្នាំ២០២២ ជាជំនួយរបស់មូនិធិ ដែលមានទឹកប្រាក់ចំនួន៥,៦លានដុល្លារសហរដ្ឋអាមេរិក ត្រូវបានអនុវត្តជា៥លើក ដើម្បីជួយជាសម្ភារ បរិក្ខារចាំបាច់





*ទិដ្ឋភាពរួមក្នុងពិធីជួបសម្ដែងការគួរសម*

ផ្សេងៗដល់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជា ហើយសង្ឃឹមថា នឹងអនុវត្តអនុស្សរណៈយោគយល់គ្នា សម្រេចបានក្នុងទឹកប្រាក់ចំនួន១០លានដុល្លារសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០២៤ខាងមុខ។ ដោយមើលឃើញអំពីលទ្ធផលអនុស្សរណៈយោគយល់គ្នានេះដែលអាចអនុវត្តសម្រេចបានលឿនដូចនេះការចុះអនុស្សរណៈយោគយល់គ្នារវាងព្រឹទ្ធសភាកម្ពុជាជាមួយនឹងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េនាពេលបន្ទាប់ នឹងកំណត់រយៈពេល៣ឆ្នាំវិញ ដោយផ្តោតសំខាន់លើផ្នែកសុខាភិបាល វិស័យអប់រំសង្គមកិច្ច។ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េនឹងនៅតែបន្តបេសកកម្មមនុស្សធម៌ ដើម្បីជួយដល់ប្រទេសកម្ពុជា និងប្រជាជនកម្ពុជាបន្តទៀត។ ជាមួយគ្នានោះ លោកប្រធានមូលនិធិបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងមន្ត្រីពាក់ព័ន្ធ ដែលបានជួយសម្របសម្រួលដល់ការបំពេញការងាររបស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនាពេលកន្លងទៅ ជាពិសេសការបំពេញទស្សនកិច្ចនាពេលនេះឱ្យបានប្រព្រឹត្តទៅដោយរលូន និងបានយូរអង្វែងល្អប្រសើរ។ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នឹងបន្តការគាំទ្រប្រទេសកម្ពុជាបន្ថែមទៀតតាមរយៈការបន្តចុះ និងអនុវត្តអនុស្សរណៈយោគយល់គ្នាដើម្បីប្រជាជន និងប្រទេសកម្ពុជា។

សម្តេចប្រធានព្រឹទ្ធសភាបានជម្រាបជូនលោកប្រធានមូលនិធិថា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០នៃព្រឹទ្ធសភា បាននាំយកជំនួយទាំងនោះទៅចែកជូនប្រជាជន មន្ទីរពេទ្យ និងអាជ្ញាធរមូលដ្ឋាននៅខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះសីហនុ។ កាយវិការដ៏សប្បុរសរបស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល ពិតជាបានរួមចំណែកជួយលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ឡើងវិញនូវការបន្តគាំទ្រវាល់បេសកកម្មការងារមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងសូមលើកទឹកចិត្តដល់គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា បន្តសហការជាមួយនឹងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល អនុលោមតាមអនុស្សរណៈ នៃការយោគយល់គ្នាស្តីពី ការផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភាកម្ពុជាឆ្នាំ២០២២ ឱ្យបានល្អប្រសើរ និងពិនិត្យលទ្ធភាពជួយសាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព និងសាលារៀន តាមបណ្តាខេត្តផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា។

សម្តេចប្រធានព្រឹទ្ធសភាមានជំនឿជឿជាក់ថា កិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល គឺជាកិច្ចសហប្រតិបត្តិការដ៏ល្អដោយផ្លែផ្កា និងប្រកបដោយប្រសិទ្ធភាពជានិច្ច។

សម្តេចប្រធានព្រឹទ្ធសភា សូមប្រសិទ្ធពរជូនលោកប្រធានមូលនិធិ និងគណៈប្រតិភូ មានសុខភាពល្អបរិបូរណ៍ ទទួលបាននូវការរីករាយក្នុងការស្នាក់នៅ និងបំពេញបេសកកម្មមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គីម សិទ្ធី)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ ជាមួយលោក Kim Jung Nam*

# ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្ដីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញជាអធិបតីភាពក្នុងសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្ដីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ*

នារសៀលថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកសន្និសីទ នៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្ដីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ នៅសណ្ឋាគារសុខាភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីគណៈប្រតិភូជាតិ និងអន្តរជាតិជាង១០០រូប មកពី៣៥ប្រទេស នៃទ្វីបទាំង៥ទូទាំងពិភពលោក។ សន្និសីទនេះ សហការរៀបចំ




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ឡើងថ្លែងសុន្ទរកថា*

ដោយសមាគមអន្តរជាតិ នៃសមាជិកសភា ដើម្បីសន្តិភាព (IAPP) នៃសហព័ន្ធសន្តិភាពសកល (UPF) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី(AVI)។

ក្នុងនាមសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានសម្ដែងនូវសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាមួយ និងជួបស្វាគមន៍ថ្នាក់ដឹកនាំជាន់ខ្ពស់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងសន្និសីទដ៏មានសារៈសំខាន់នាពេលនោះ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានកត់សម្គាល់ឃើញថា សភាពការណ៍ពិភពលោកបន្តប្រែប្រួលយ៉ាងឆាប់រហ័សប្រកបដោយភាពស្មុគស្មាញ ហានិភ័យខ្ពស់ និងពិបាកប៉ាន់ស្មាន ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយកាន់តែស្រួចស្រាល់ សង្គ្រាមប្រដាប់អាវុធ សង្គ្រាមចិត្តសាស្ត្រ វោហារសាស្ត្រគំរាមវាយប្រហារគ្នា និងសកម្មភាពបង្កហេតុថ្មីៗបានកើតមានឡើងជាបន្តបន្ទាប់ ដែល

សុទ្ធសឹងតែជាមូលហេតុធ្វើឱ្យស្ថានភាពពិភពលោកបន្តធ្លាក់ចុះកាន់តែអាក្រក់ បង្កើនហានិភ័យចំពោះសន្តិភាព និងការអភិវឌ្ឍសម្រាប់ប្រទេសក្រីក្រ ប្រទេសតូច និងមធ្យម។ ជាមួយគ្នានោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានសង្កត់ធ្ងន់ថា សន្តិភាពមិនមែនគ្រាន់តែជាគោលដៅដែលចង់បានសម្រាប់ពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែសន្តិភាព គឺជាមធ្យោ-បាយដែលត្រូវប្រកាន់យកផងដែរ ដូចប្រសាសន៍របស់សម្តេចតេជោ **ហ៊ុន សែន** ថា សង្គ្រាមមិនអាចបញ្ចប់សង្គ្រាមបានទេ មានតែការចរចា ការសន្ទនាប៉ុណ្ណោះ ទើបអាចបញ្ចប់សង្គ្រាមបាន។ ការស្វែងរកសន្តិភាព គឺលំបាកណាស់ ប៉ុន្តែភាពជាម្ចាស់លើបញ្ហាជាតិ និងការស្វែងរកដំណោះ-ស្រាយប្រកបដោយសុឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មុតមាំ ទើបទទួលបាននូវសន្តិភាព។ ទន្ទឹមនឹងនោះ ទស្សនវិជ្ជានយោ-បាយ សន្តិភាពគួរត្រូវបានប្រកាន់យក និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ សន្តិភាពរបស់ប្រទេសមួយ គឺអាស្រ័យយ៉ាងខ្លាំងលើសន្តិភាពក្នុងតំបន់ និងពិភពលោក ពីព្រោះក្នុងពិភពលោកបច្ចុប្បន្ន ប្រទេសនីមួយៗ ត្រូវអាស្រ័យគ្នាទៅវិញទៅមក ទាំងខាងនយោបាយ សេដ្ឋកិច្ច សង្គម វប្ប-ធម៌។ល។ ដូច្នេះ ការថែរក្សា ពង្រឹង និងពង្រីកសន្តិភាពក្នុងពិភពលោក គឺជាមូលដ្ឋានគ្រឹះនៃផលប្រយោជន៍ជាយុទ្ធ-សាស្ត្រ និងរយៈពេលយូរទាំងអស់គ្នា។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆែព ខន** បានបញ្ជាក់ថា កម្ពុជាបច្ចុប្បន្នបានក្លាយជាមជ្ឈមណ្ឌលនៃសន្តិភាពសម្រាប់តំបន់មេគង្គ និងអាស៊ាន ហើយដើម្បីចូលរួមចំណែកថែរក្សា ពង្រឹង និងពង្រីកសន្តិភាពក្នុងពិភពលោក កម្ពុជាបានបញ្ជូនទាហានមួកខៀវ ដើម្បីគាំទ្រដល់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ កម្ពុជាបានបន្តអនុវត្តគោលនយោបាយការបរទេសដោយផ្អែកលើច្បាប់កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយនឹងប្រទេសទាំងអស់នៅលើសកលលោក និងអង្គការអន្តរជាតិនានា។

ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សសេរីភាព នៃការបញ្ចេញមតិត្រូវមានតុល្យភាពជាមួយនឹងការពង្រឹងនីតិរដ្ឋ និងការថែរក្សាអធិបតេយ្យជាតិ លើកកម្ពស់គុណធម៌ សីលធម៌ វប្បធម៌របស់ប្រទេសជាតិនីមួយៗ ដើម្បីធានាថា ប្រជាធិបតេយ្យមិនរអិលធ្លាក់ចូលក្នុងអនាធិប-តេយ្យ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆែព ខន** បានមានប្រ-សាសន៍ទៀតថា អភិបាលកិច្ចល្អជាធាតុផ្សំដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេស ដែលត្រូវតែជាអភិបាលកិច្ចដែលយកផលប្រយោជន៍របស់ប្រជាជនជាស្នូល យកប្រជា-ជនជាគោលដៅ នៃការបម្រើ ធ្វើយ៉ាងណាបម្រើប្រជាជនឱ្យបានល្អ ប្រជាជនពេញចិត្តចំពោះសេវាសាធារណៈជឿ-





*ទិដ្ឋភាពអ្នកចូលរួមក្នុងសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្តីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ*




*ទិដ្ឋភាពក្នុងសន្និសីទនៃភាពជាអ្នកដឹកនាំអន្តរជាតិ ស្ដីពីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ*

ទុកចិត្ត។ ជាមួយគ្នានេះ ប្រទេសកម្ពុជាបានអនុវត្តន៍ និងបន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅ និងទូលំទូលាយប្រកបដោយផ្លែផ្កា ដែលបានធានាដល់ការលើកកម្ពស់អភិបាលកិច្ច នៃគ្រប់ស្ថាប័ន គ្រប់ថ្នាក់ ការពង្រឹងយុត្តិធម៌ សមធម៌សង្គម ការកសាងធនធានមនុស្សប្រកបដោយគុណភាព ការផ្តល់សេវាសាធារណៈជូនប្រជាជនប្រកបដោយប្រសិទ្ធភាព និងការជឿទុកចិត្ត ការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព តាមរយៈបរិវត្តកម្មឌីជីថល ការបង្កើតការងារ ការផ្តល់ជូនប្រជាជននូវកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ ការការពារបរិស្ថាន និងការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការកែលម្អជីវភាពរបស់ប្រជាជនឥតឈប់ឈរ។ ជាងនេះទៅទៀត ការអភិវឌ្ឍត្រូវតែជាការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវធ្វើឱ្យមានតុល្យភាពរវាងការអភិវឌ្ឍខាងមូលដ្ឋានសម្ភារ និងការអភិវឌ្ឍខាងមូលដ្ឋានស្មារតី គឺមានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍខាងវប្បធម៌ សីលធម៌ គុណធម៌ ដើម្បីធានាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុខដុមរមនាសង្គម និងវិបុលភាព ប្រជាជនរស់នៅបានសុខទាំងផ្លូវកាយ និងផ្លូវចិត្ត។

ផ្ដើមចេញពីសន្និសីទនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** សង្ឃឹមថាសន្តិភាពនឹងផ្សាយទូទៅពេញសកលលោក និងសូមឱ្យពិភពលោកទាំងមូលមានសន្តិភាព និងការអភិវឌ្ឍ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិ*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ នីតិកាលទី៧ នៅការិយាល័យបោះឆ្នោតលេខ០២៣១ មណ្ឌលវត្តកោះ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ នីតិកាលទី៧ នៅការិយាល័យបោះឆ្នោតលេខ ០០២៧ ស្ថិតក្នុងវិទ្យាល័យបឹងត្របែក សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃសុក្រ ទី៧ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពផ្ដល់ភ្លើងបូជាសពលោកជំទាវព្រឹទ្ធាចារ្យវប្បធម៌សិល្បៈខ្មែរ **ម៉ិញ ក្ញុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅខាងមុខវត្តបទុមវតី ស្ថិតក្នុងសង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **អ៊ុក ដាមរី** សមាជិកគណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ នៃរដ្ឋសភា និងជាតំណាងរាស្ដ្រមណ្ឌលខេត្តកណ្ដាល នៅផ្ទះលេខ១២៦-១២៨ ផ្លូវរុក្ខវិថីអេកូសាន់រាយ ស្ថិតក្នុងបុរីប៉េងហួតបឹងស្នោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ នីតិកាលទី៧ នៅការិយាល័យបោះឆ្នោតលេខ១៦៩៧ សាលាគរុកោសល្យវិក្រឹតការក្រុងតាខ្មៅ ក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។



# គណៈកម្មការទី១០ ព្រឹទ្ធសភា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូ មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ




*ឯកឧត្តម ម៉ម ប៊ុននាង ជួបពិភាក្សាការងារជាមួយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ*

នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung-Nam ប្រធានមូលនិធិ ក្នុងគោលបំណងពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកមនុស្សធម៌ និងការបង្កើនប្រសិទ្ធភាព នៃការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងគណៈកម្មការអង្កេតបោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ឱ្យកាន់តែមានប្រសិទ្ធភាព គណនេយ្យភាព សំដៅលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនទីទ័លក្រ និងក្រុមជនងាយរងគ្រោះកម្ពុជាឱ្យបានកាន់តែប្រសើរឡើង។

ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភា បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញបេសកកម្មមនុស្សធម៌ជាលើកទី២ នៅប្រទេសកម្ពុជា និងចូលរួមអបអរសាទរជាមួយនឹងលោកប្រធាន និងគណៈប្រតិភូ ដែលត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ប្រោសព្រះរាជទានគ្រឿងឥស្សរិយយស ហើយត្រូវបានបំពាក់ជូនដោយសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

ឯកឧត្តមប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល ព្រមទាំង




*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*




*គណៈកម្មការទី១០ព្រឹទ្ធសភាថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ*

គណៈប្រតិភូបានឆ្លៀតពេលដ៏មមាញឹកមកបំពេញបេសកកម្មមនុស្សធម៌នៅកម្ពុជា និងបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធាន មកជួយឧបត្ថម្ភគាំទ្រដល់ប្រជាជនទីទ័លក្រកម្ពុជា ជាពិសេសក្រុមជនងាយរងគ្រោះ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង។ ឯកឧត្តមប្រធានបានមានប្រសាសន៍បន្ថែមថា ជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល មិនត្រឹមតែជួយដល់ប្រជាជនក្រីក្រប៉ុណ្ណោះទេ គឺថែមទាំងបានចូលរួមយ៉ាងធំធេងដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

ឯកឧត្តម **ម៉ម ប៊ុននាង** បានបញ្ជាក់ថា មកទល់នឹងបច្ចុប្បន្ននេះ ព្រឹទ្ធសភាកម្ពុជាបានទទួលជំនួយមនុស្សធម៌ពីមូលនិធិចែករំលែកសង្គ្រោះជីវិតសកលចំនួន៤លើកមកហើយ ដែលរួមមាន៖សម្ភារៈវេជ្ជសាស្ត្រ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ និងសម្ភារៈសម្រាប់ក្មេងៗ។ ជំនួយមនុស្សធម៌ខាងលើ ត្រូវបានគ្រប់គ្រង និងចាត់ចែងប្រកបដោយប្រសិទ្ធភាពពីសំណាក់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ហើយត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈបណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយនានា។

ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ក្នុងនាមជាសេនាធិការផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា បានធ្វើបទបង្ហាញជូនអង្គប្រជុំអំពី សកម្មភាព និងលទ្ធផល ដែលគណៈកម្មការបាននាំយកជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល ដែលចែកជូនដល់ក្រសួង ស្ថាប័ន ព្រមទាំងនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តបាត់ដំបង ព្រមទាំងមន្ទីរពេទ្យមួយចំនួនទៀត ដូចជា៖ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យគន្ធបុប្ផា (ទាំងនៅភ្នំពេញ និងខេត្តសៀមរាប) មន្ទីរពេទ្យកាលម៉ែត្រ...។ល។

លោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល បានសម្តែងនូវភាពសប្បាយរីករាយ និងវាយតម្លៃខ្ពស់ ដោយបានមើលឃើញនូវសកម្មភាពដ៏មមាញឹក និងភាពរស់រវើករបស់គណៈកម្មការទី១០ព្រឹទ្ធសភា ក្នុងការនាំយកអំណោយមនុស្សធម៌ចែកជូនដល់អង្គភាពនៅតាមមូលដ្ឋាន និងប្រជាពលរដ្ឋក្រីក្រ និងក្រុមជនងាយរងគ្រោះ។ លោកប្រធានមូលនិធិ បានសន្យានឹងខិតខំរៀបចំជំនួយមនុស្សធម៌មកព្រឹទ្ធសភាកម្ពុជាឱ្យបានកាន់តែច្រើន និងឆាប់រហ័ស ហើយជាជំនួយដែលឆ្លើយតបនឹងសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ជាពិសេសទាក់ទងនឹងវិស័យសុខាភិបាល វិស័យអប់រំ និងសម្ភារសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។

គណៈកម្មការទី១០ព្រឹទ្ធសភា និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល តាមរយៈកិច្ចប្រជុំខាងលើ បានឯកភាពគ្នាក្នុងការជួយឧបត្ថម្ភ និងគាំទ្រលើគម្រោងសាងសង់មន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ និងគម្រោងសាងសង់មជ្ឈមណ្ឌលស្តានីតិសម្បទាសម្តេចតេជោ **ហ៊ុន សែន** បន្ថែមលើអនុស្សរណៈដែលបានធ្វើនាពេលកន្លងទៅ៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាល អាជ្ញាធរឃុំចំនួន៤ ក្នុងស្រុកក្រូចឆ្មារ



*ឯកឧត្តម ឆាយ វណ្ណា និងឯកឧត្តម ឡាន់ ឆន*

ដោយមានការណែនាំ និងអនុញ្ញាតពីឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នាព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ រួមមាន៖ ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការក្រុម និងឯកឧត្តម **ឡាន់ ឆន** សមាជិកក្រុម បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរ និងក្រុមប្រឹក្សាឃុំចំនួន៤ គឺឃុំកោះពីរ ឃុំកំពង់ទ្រាស់ ឃុំព្រែកអាជី និងឃុំទ្រា នៃស្រុកក្រូចឆ្មារ ដោយមានការអញ្ជើញចូលរួមពីក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សរុបចំនួន៣២នាក់ នៅសាលាស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។

ពិធីសំណេះសំណាលនោះ រៀបចំឡើងដើម្បីស្តាប់សំណូមពរ និងគោលការណ៍ចាំបាច់របស់ក្រុមប្រឹក្សាឃុំ ផ្តោតសំខាន់លើការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងរដ្ឋបាលឃុំ ព្រមទាំងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។ ជាពិសេសរួមគ្នាចែករំលែកនូវបទពិសោធន៍ ក៏ដូចជាឈ្វេងយល់អំពីការអនុវត្តតួនាទីភារកិច្ចរបស់ឃុំនីមួយៗទៅវិញទៅមក ដើម្បីរួមគ្នាធ្វើការអភិវឌ្ឍឃុំរៀងៗខ្លួនឱ្យកាន់តែប្រសើរថែមទៀត។

បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍របស់អាជ្ញាធរ និងក្រុមប្រឹក្សាឃុំទាំង៤រួចមក ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរឃុំទាំង៤ ក្នុងការបម្រើសេវារដ្ឋបាលសាធារណៈជូនបងប្អូនប្រជាពលរដ្ឋ ដែលទទួលបាននូវលទ្ធផលល្អប្រសើរ។ បើទោះបីជាលទ្ធផលដែលសម្រេចបាននាពេលកន្លងទៅ ខ្លះវិជ្ជមាន និងអវិជ្ជមានក្តី ឯកឧត្តមបានជំរុញ និងលើកទឹកចិត្តឱ្យអាជ្ញាធរ-




*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរ និងក្រុមប្រឹក្សាឃុំចំនួន៤*



ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរ និងក្រុមប្រឹក្សាឃុំចំនួន៤

ឃុំបន្តយកចិត្តទុកដាក់អនុវត្តតួនាទីរបស់ខ្លួននៅក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀត ដើម្បីធ្វើការកែលម្អឱ្យលទ្ធផលដែលអវិជ្ជមានប្រែក្លាយទៅជាវិជ្ជមានវិញ។ ជាមួយគ្នានោះ ត្រូវបន្តការយកចិត្តទុកដាក់ចំពោះការផ្ដល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសត្រូវធ្វើយ៉ាងណាចូលរួមស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលាពាក់ព័ន្ធទៅនឹងបញ្ហាប្រឈម សេចក្ដីត្រូវការ និងសំណូមពររបស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរៀងៗខ្លួន។

ចំពោះបញ្ហាប្រឈម និងសំណូមពរដែលនៅសេសសល់ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគ្រប់យន្តការនានា ដើម្បីចូលរួមរកវិធីសាស្ត្រដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ដោយឡែកនាព្រឹកថ្ងៃដដែលនោះ ក្រុមមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានយកឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ចំនួន១៨៥ប្រអប់តូច ទៅប្រគល់ជូនដល់ការិយាល័យសុខាភិបាលស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)






ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ផ្ដល់ឧបករណ៍តេស្តរហ័ស កូវីដ-១៩ ដល់ការិយាល័យសុខាភិបាលស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការនយោបាយ AIPA-44 ដើម្បីពិភាក្សាលើ Draft Resolutions នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈកម្មការជួបជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



-នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ គណៈកម្មការទី២ព្រឹទ្ធសភាជួបជាមួយគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៤-២០២៦) និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន៧ និងត្រៀមឡើងមានយោបល់នៅក្នុងសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។

❈ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នារសៀលថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យត្រៀមផ្តល់យោបល់ក្នុងសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤ លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោត

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ

ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនខ្មែរ អេឡិកទ្រិខល ផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្តាល អានុភាព៧០មេហ្គាវ៉ាត់ ផ្គួបគ្នាជាមួយ គម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងវាលថ្មកំបុត អានុភាព ១០០មេហ្គាវ៉ាត់ ខេត្តកោះកុង

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនឡាក់ឃី សូឡា ផៅវ័រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរ ដោយថាមពលពន្លឺព្រះអាទិត្យអានុភាព៨០មេហ្គាវ៉ាត់ ខេត្តព្រៃវែង

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់ គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយ ថាមពលពន្លឺព្រះអាទិត្យអានុភាព១៥០មេហ្គាវ៉ាត់ ខេត្តពោធិ៍សាត់

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់ គម្រោងអភិវឌ្ឍស្ថានីយ ផលិតអគ្គិសនីដើរដោយ ថាមពលពន្លឺព្រះអាទិត្យអានុភាព៦០មេហ្គាវ៉ាត់ ខេត្តស្វាយរៀង

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់ គម្រោងអភិវឌ្ឍស្ថានីយ ផលិតអគ្គិសនីដើរដោយ ថាមពលពន្លឺព្រះអាទិត្យអានុភាព៦០មេហ្គាវ៉ាត់ ខេត្តកំពង់ឆ្នាំង

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការ ធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្ទឹងមេទឹក ហាយដ្រូផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងមេទឹក អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង។



-នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈកម្មការ ជួបជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យសិក្សាលើ សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោត នៅ សាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

❋លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ ទី៨ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការ គណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាង ក្រោម៖



-នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ត្រៀមដើម្បី ពិនិត្យ និងសម្រេចចុងក្រោយលើការផ្តល់ធាតុចូលលើ សេចក្តីព្រាងសេចក្តីសម្រេចរបស់គណៈកម្មាធិការសមាជិកសភាស្ត្រីអាយប៉ា (WAIPA) និងការងារត្រៀមផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។

-នារសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ គណៈកម្មាធិការសមាជិកសភាស្ត្រីអាយប៉ា (WAIPA) នៃមហាសន្និបាត លើកទី៤៤ ដើម្បីពិនិត្យ និងសម្រេចចុងក្រោយលើការផ្តល់

ធាតុចូលលើសេចក្ដីព្រាងសេចក្ដីសម្រេចរបស់គណៈកម្មាធិការសមាជិកសភាស្ត្រីអាយប៉ា (WAIPA) និងការងារត្រៀមផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មច្បាប់បោះឆ្នោត

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនខ្មែរ អេឡិកទ្រីខល ផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងឫស្សីជ្រំកណ្ដាល អានុភាព៧០មេហ្គាវ៉ាត់ ផ្ចួបគ្នាជាមួយគម្រោងអភិវឌ្ឍវារីអគ្គិសនី ស្ទឹងវាលថ្មកំបុត អានុភាព១០០មេហ្គាវ៉ាត់ ខេត្តកោះកុង

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនឡាក់ឃី សូឡា ផៅវ័រ ឯ.ក សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព៨០មេហ្គាវ៉ាត់ ខេត្តព្រៃវែង

៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព១៥០មេហ្គាវ៉ាត់ ខេត្តពោធិ៍សាត់

៥-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយ ផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព៦០មេហ្គាវ៉ាត់ ខេត្តស្វាយរៀង

៦-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្នេថេក ខូអិលធីឌី សម្រាប់គម្រោងអភិវឌ្ឍស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព៦០មេហ្គាវ៉ាត់ ខេត្តកំពង់ឆ្នាំង

៧-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្ទឹងមេទឹក ហាយដ្រូផៅវ័រ សម្រាប់គម្រោងអភិវឌ្ឍវារីអគ្គិសនីស្ទឹងមេទឹក អានុភាព១៥០មេហ្គាវ៉ាត់ ខេត្តកោះកុង។

❈ នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ថវិកា និងរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារប្រចាំខែកក្កដា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា



បានដឹកនាំកិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) នៅសាលប្រជុំពិសេស (VIP3) ព្រឹទ្ធសភា លើ៖

១-សេចក្ដីរាយការណ៍ពីវឌ្ឍនភាពការងារ ដោយឯកឧត្តម **ឈឹម សុទ្ធគុណ** អគ្គនាយក នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

២-សេចក្ដីរាយការណ៍ពីវឌ្ឍនភាពការងារ ដោយឯកឧត្តម **ព្រហ្ម ថិរៈ** អគ្គនាយក នៃអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ពិធីការ និងព័ត៌មាន នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា និងតំណាងជម្រាបអង្គប្រជុំអំពីការងារពាក់ព័ន្ធ និងបញ្ហាផ្សេងៗ។



❈នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំពិភាក្សាការងារសំខាន់ៗរបស់ក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។




❈នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំពិនិត្យ និងផ្ដល់ធាតុចូលលើសេចក្ដីព្រាងសេចក្ដីសម្រេចចំនួន៤ ដែលត្រូវបានស្នើឡើងក្នុងគណៈកម្មាធិការកិច្ចការសេដ្ឋកិច្ច (AIPA) នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ច្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈប្រតិភូសភាកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើការផ្ដល់ធាតុចូលលើសេចក្ដីព្រាងសេចក្ដីសម្រេច នៃគណៈកម្មាធិការកិច្ចការសេដ្ឋកិច្ច នៃមហាសន្និបាតអាយប៉ាលើកទី៤៤ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ នៅទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូណេស៊ី នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨



❋នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយកម្មករ និយោ-ជិត នៅរោងចក្រថូភេកអេឡិកទ្រីក ឯ.ក ខេត្តពោធិ៍សាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិសាររ៉ែន ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖

-ទទួលព្រះសង្ឃនិមន្តមកពីវត្តបឹងខ្នា និងវត្តព្រះតាចាន់ ចំនួន៣០អង្គ ព្រមទាំងតាជី យាយជី និងប្រជាជនក្រីក្រ ចំនួន១៥០នាក់ អញ្ជើញមកទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍ កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងបានប្រគេន ចង្ហាន់ពេលព្រឹក និងបច្ច័យដល់ព្រះសង្ឃ និងប្រជាពលរដ្ឋ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង ដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន និងទំនប់-ទឹក នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹក ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង ចុះពិនិត្យមន្ទីរពេទ្យម៉ុង ឫទ្ធីសែនជ័យ និងហេដ្ឋារចនាសម្ព័ន្ធ នានានៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធីសែនជ័យ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃ ទី២ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង ចុះពិនិត្យស្ថានភាពទំនប់ទឹក និងចុះពិនិត្យកសិដ្ឋានចិញ្ចឹម ជ្រូក នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមអបអរសាទរពិធីសម្ពោធកំពង់ផែទេសចរណ៍ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី៦ ខែ កក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង ដឹកនាំក្រុមអ្នកជំនាញកសិកម្ម ចូលរួមដាំកូនដើមឈើអូញ-ម៉ូញ កូនត្របែកព្រៃ និងកូនសាកូរ៉ា ដើម្បីចូលរួមថែរក្សា ការពារបរិស្ថានជាមួយរាជរដ្ឋាភិបាល នៅឃុំសែនជ័យ ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង ចុះដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសកសិកម្ម រៀបចំសម្អាត ដី ដើម្បីរៀបចំដាំដើមធ្នង់ និងកូនដើមឈើចម្រុះសរុប ៩៨.៩០០ដើម ដើម្បីចូលរួមអបអរសាទរក្នុងពិធីរុក្ខទិវា៩ កក្កដា នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ អញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាតំបន់កសិ-ទេស-ចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនជ័យ ស្រុកសំរោង-ទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំង

ចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ទឹក អគ្គិសនី នៅលើផ្ទៃដី១៧២ហិកតា ដើម្បីត្រៀមបម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងនាំយកសម្លៀកបំពាក់ ថវិកា ចែកជូនពួកគាត់ ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរសម្រាកព្យាបាល និងសម្ភព ឧកញ៉ា ម៉ុង នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យចម្ការដូងក្រអូប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក ហេដ្ឋារចនាសម្ព័ន្ធនានា នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងបាននាំយកអំណោយ និងថវិកាចែកជូនពួកគាត់ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម និងកសិឧស្សាហកម្ម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ទឹក អគ្គិសនី នៅលើផ្ទៃដី១៧២ហិកតា ដើម្បីត្រៀមបម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣។



❈នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលកម្មករនិយោជិតចំនួន៦.៨៦៨នាក់ នៃរោងចក្រចំនួន១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅស្រុកក្រគរ ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកកំពង់ត្របែក និងស្រុកមេសាង ខេត្តព្រៃវែង នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣។



❈នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាសុី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញនាំយកនូវទេយ្យទានជាសម្ភារៈ គេសជ្ជៈ និងថវិកាមួយចំនួនទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា

នៅវត្តព្រែកប្រាំង វត្តស្បែង វត្តព្រះពុទ្ធពរ វត្តសុវណ្ណវារី-ព្រែកតាទែន វត្តមុនីប្រសិទ្ធីវង្ស និងវត្តច័ន្ទបុរីវង្ស នៅស្រុកពញាឮ ខេត្តកណ្តាល។



❈នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាដាក់កូរោនផ្កាគោរពវិញ្ញាណក្ខន្ធសពលោកជំទាវមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ **ទុំ សារឿន** ភរិយារបស់ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានទទួលមរណភាពក្នុងជន្មាយុ៦៦ឆ្នាំ ដោយរោគាពាធ នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។



❈នាថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សា ស្មៀន ដើម្បីពិនិត្យការងារត្រៀមសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ នៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ សង្កាត់ស្ទោរ សង្កាត់ឪឡោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិបឹងដំរ និងភូមិព្រៃទឹង ឃុំព្រៃទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាថ្ងៃទី២ និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិស្វាយទាប ភូមិក្បាលបឹង និងភូមិទួលជ្រៃ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាថ្ងៃទី៥ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិអំពិលក្រៅ ព្រមទាំងជួបសំណេះសំណាលក្រុមប្រឹក្សាឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។




-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំទី៦ គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ទុំ សារឿន** ត្រូវជាភរិយាឯកឧត្តម **គឹម ឆា** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ និងជាលេខាធិការគណៈកម្មការទី៦ ព្រឹទ្ធសភា នៅភូមិវាលយន្ត សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រធានក្រុមប្រឹក្សាស្រុក សមាជិក សមាជិកាក្រុមប្រឹក្សាឃុំទាំង១១ ក្រុមយុវជន និងយុវនារី នៅស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នារសៀលថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមនារីចំនួន១៣០នាក់ នៅស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិគោករកា ឃុំព្រៃទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង

នារសៀលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្ទង់ផ្ទះ នៅភូមិពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❋នាថ្ងៃទី១ និងថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចុះពិនិត្យពីវឌ្ឍនភាព ព្រមទាំងជួយជំរុញតួនាទីសំខាន់ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ នៅខេត្តពោធិ៍សាត់។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលក្រុមប្រឹក្សាឃុំទាំង១៨ឃុំ នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** នាព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

-ទស្សនកិច្ចការងារនៅខេត្តសៀមរាប ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ស្ដីពី ការប្រឆាំងអំពើពុករលួយ និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នាថ្ងៃទី៨ និងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសំណេះសំណាលការងារ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការ និងត្រៀមរៀបចំការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមកិច្ចប្រជុំត្រួតពិនិត្យការងារ ផែនការ និងទិសដៅការងារបន្ត ពិសេសការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តម **ពេជ្រ ជីវ័ន្ត** នៅស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិភាក្សាការងារអំពីការទទួលផែនការសម្រាប់អនុវត្តបន្តក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តម **ស្បោង សារ៉ាត់** នៅខេត្តព្រៃវែង នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣។

-នាំយកកោដ្ឋជាចម្លាក់អំពីថ្មភ្នំ មកដាក់តាំងក្នុងបូជនីយដ្ឋាន (ស្តូប) ដែលមានអាយុកាល៣៣ឆ្នាំ របស់ស្រុកពាមជរ ទើបជួសជុលរួច និងព្រមទាំងអញ្ជើញជាអធិបតីភាពក្នុងពិធីប្រសិទ្ធីសាជាថ្មី ដើម្បីទទួលបានបារមីស័ក្តិសិទ្ធិសម្រាប់គោរពបូជា ជាពិសេសពិធីគោរពវិញ្ញាណក្ខន្ធទិវាចងចាំ២០ឧសភា នៅស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិភាក្សាការងារអំពីការប្រគល់ផែនការអនុវត្តបន្តក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

❋នាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបួងសួងសុំសេចក្ដីសុខ នៅបរិវេណប្រាសាទភ្នំបាណន់ ព្រមទាំងជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកបាណន់ ខេត្តបាត់ដំបង។

❋ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង នារសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងស្រុកចំនួន៤គឺ៖ ស្រុកសំឡូត ស្រុករតនៈមណ្ឌល ស្រុកភ្នំព្រឹក ស្រុកកំរៀង និងស្រុកមោងឫស្សី

ខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាថ្ងៃទី៧ ថ្ងៃទី៨ និងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារអនុវិទ្យាល័យព្រែកនរិន្ទ ចំនួន១ខ្នង កម្ពស់២ជាន់ មាន១២បន្ទប់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។



❈នារសៀលថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា ចំនួន២ខ្នង មាន១២បន្ទប់ នៅបឋមសិក្សាឈើទាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកបាណន់ ខេត្តបាត់ដំបង។

❈ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៨ឃុំគឺ ឃុំតាទៃលើ ឃុំស្រែអំបិល ឃុំជំនាប់ ឃុំដីផាត ឃុំជ្រោយស្វាយ ឃុំបឹងព្រាវ ឃុំកោះស្ដេច និងឃុំភ្ញីមាស នៅខេត្តកោះកុង នាថ្ងៃទី៣ ដល់ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤ឃុំគឺ ឃុំព្រែកខ្សាច់ ឃុំឫស្សីជ្រុំ ឃុំថ្មស និងឃុំតានូន នៅខេត្តកោះកុង នាថ្ងៃទី១០ និងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋនៅសង្កាត់ដងទង់ ខេត្តកោះកុង នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤ឃុំគឺ ឃុំប៉ាក់ខ្លង ឃុំពាមក្រសោប ឃុំប្រឡាយ និងឃុំថ្មដូនពៅ នៅខេត្តកោះកុង នាថ្ងៃទី១៤ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋ ក្រោមអធិបតីភាពលោកជំទាវ **មិថុនា ភូថង** អភិបាលខេត្តកោះកុង នៅឃុំដងពែង ខេត្តកោះកុង នាព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន២ឃុំគឺ ឃុំជីខលើ និងឃុំអណ្ដូងទឹក ខេត្តកោះកុង ខេត្តកោះកុង នាថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះទៅពិនិត្យការព្យាបាលជំងឺភ្នែក ផ្តល់ឱសថ និងវ៉ែនតាជូនបងប្អូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ដោយក្រុមវេជ្ជបណ្ឌិតមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅសាលាបឋមសិក្សា

ទួលគោក ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមប្រជុំជាមួយគណៈបញ្ជាការឯកភាពសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីបែងចែកភារកិច្ចក្នុងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ សណ្ដាប់ធ្នាប់តាមដងផ្លូវ និងការងារច្រកចេញ-ចូលតែមួយ-ឱ្យកាន់តែប្រសើរ នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣។



-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាទាំង១០ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយឯកសារសំខាន់ៗសម្រាប់បម្រើឱ្យការអនុវត្តជាក់ស្តែងក្នុងយុទ្ធនាការ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

※ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈ-កម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចសង្ឃសន្និបាតមន្ត្រីសង្ឃរាជធានីភ្នំពេញ ឆ្នាំ២០២៣ នៅវត្តព្រះពុទ្ធពុទ្ធមានបុណ្យ ខណ្ឌ៧មករា វត្ត



នន្ទមុនី ខណ្ឌមានជ័យ និងវត្តនន្ទមណីរាម ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី២៥ ដល់ថ្ងៃទី២៦ និងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលបងប្អូនកម្មករនិយោជិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតី-តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ស្ថិតនៅជាប់វត្តព្រៃស្ពឺ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។



-ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ម៉ិញ កុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានទទួលមរណភាពក្នុងជន្មាយុ៧៧ឆ្នាំ ដោយរោគាពាធ នៅបុរីប៉េងហួតបឹងស្នោរ គេហដ្ឋានលេខ៤៣ ផ្លូវលេខD០៦ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខឯកឧត្តម **ចាន់ ផូ** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ដែលកំពុងសម្រាកថែទាំសុខភាពនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភកន្សែងពោះគោ និងថវិកាមួយចំនួន នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលសហភាពសហព័ន្ធយុវជនកម្ពុជា ក្រុមចលនាស្ត្រី និងអាជ្ញាធរឃុំដំណាក់អំពិល ចំនួន១៦៥ នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៥ភូមិគឺ ភូមិទម្លាប់ខ្ពស់ជើង ភូមិពងទឹក ភូមិជ្រៃមង្គល ភូមិក្តាន់រយ និងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាថ្ងៃទី៤ ថ្ងៃទី៦ ដល់ថ្ងៃទី៧ ថ្ងៃទី១៦ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

-សំណេះសំណាលប្រជាពលរដ្ឋ និងនាំយកទៀនវស្សាប្រគេនព្រះសង្ឃ នៅវត្តដំណាក់អំពិល ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយរៀង នាថ្ងៃទី២៣ ថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៧ ថ្ងៃទី១៤ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីសម្ពោធសមិទ្ធផល រួមមាន៖ ផ្លូវថ្នល់ ព្រះវិហារ អន្តេវាសិកដ្ឋាន ខ្លោងទ្វារ និងសាលាបាលី ក្នុងវត្តជម្ពូព្រឹក្សា ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាវត្តអណ្តូងពោធិ៍ នៅឃុំអណ្តូងពោធិ៍ ស្រុករមាសហែក ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣។

-ចុះពិនិត្យស្ថានភាពទូទៅ ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ ប្រធានភូមិ អនុប្រធានភូមិ សួរសុខទុក្ខប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១ ថ្ងៃទី៤ ដល់ថ្ងៃទី៥ ថ្ងៃទី៧ ថ្ងៃទី៩ ដល់ថ្ងៃទី១៣ និងទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាភូមិ ឃុំ និងប្រជាពលរដ្ឋនៅភូមិជើងភ្នំ ឃុំធម្មតាអរ និងភូមិវល្លិប្រេង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧រដ្ឋសភា នាព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧រដ្ឋសភា នៅឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ នៅឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

❋នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានបេតុង

ឆ្លងកាត់ប្រឡាយ៩៩ ស្ថិតក្នុងឃុំព្រៃយុថ្កា ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅស្រុកកោះអណ្ដែត ខេត្តតាកែវ។

❉ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងស្រុកចំនួន៣គឺ ស្រុកព្រះនេត្រព្រះ ស្រុកអូរជ្រៅ និងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននាថ្ងៃទី៥ ថ្ងៃទី៩ និងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នាយប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ និងមេភូមិ ដើម្បីស្វែងយល់ពីការអនុវត្តច្បាប់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❉នាថ្ងៃទី២ និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន១៣៥០នាក់ ក្រោមអធិបតីភាពសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង។

❉ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសម្ពោធអគារសិក្សា២ខ្នង មាន១២បន្ទប់ នៅអនុវិទ្យាល័យរហាត់ទឹក ឃុំរហាត់ទឹក ស្រុកមង្គលបូរី ផ្លូវបេតុងប្រវែង៧គីឡូម៉ែត្រតភ្ជាប់ពីផ្លូវជាតិលេខ៦ ឃុំឈ្នួរមានជ័យដល់វត្តប្រាសាទស្រះកណ្ដាល (ខ្វាស់) ឃុំ



ប៉ុស្សូវ ស្រុកព្រះនេត្រព្រះ និងអគារសិក្សា២ខ្នង មាន១០បន្ទប់ អគារទីចាត់ការ១ខ្នង មាន៣បន្ទប់ នៅអនុវិទ្យាល័យទ្រាស់ ឃុំទ្រាស់ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ លោកគ្រូ អ្នកគ្រូ លោកគ្រូពេទ្យ អ្នកគ្រូពេទ្យ និងកងកម្លាំងសមត្ថកិច្ច ដើម្បីស្ដាប់សំណូមពរ និងបញ្ហាប្រឈមនានា ព្រមទាំងឧបត្ថម្ភសារុង ជួយការសាងសង់របងសាលា លុបស្រះទឹក កុំព្យូទ័រយួរដៃ និងថវិកាមួយចំនួន នៅសាលាឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ សាលាបឋមសិក្សាគោកអំពិល ឃុំស្លក្រាម ស្រុកស្វាយចេក និងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣។



-ដឹកនាំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំទាំង៨ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងកូនដើមឈើផ្ទង់ នាថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមប្រជុំជាមួយស្នងការនគរបាល ស្នងការរងនគរ-

បាល លោកអភិបាលស្រុក លោកប្រធានក្រុមប្រឹក្សាស្រុក នៅក្រុងសិរីសោភ័ណ ស្រុកថ្មពួក និងឃុំស្លក្រាម ឃុំតាបែន ឃុំរលួស ឃុំទ្រាស់ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យដើម្បីពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់សង្គម ពិសេសភូមិ ឃុំមានសុវត្ថិភាព សម្អាតបរិស្ថាន តុបតែងលម្អសោភ័ណភាពនៅមូលដ្ឋាន ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាថ្ងៃទី១ ដល់ថ្ងៃទី៤ ថ្ងៃទី៧ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលបងប្អូនប្រជាពលរដ្ឋ នៅស្រុកព្រះនេត្រព្រះ ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ភូមិអំពិលព្រង់ ឃុំទ្រាស់ ស្រុកស្វាយចេក ស្រុកភ្នំស្រុក ស្រុកអូរជ្រៅ ស្រុកពួក ក្រុងប៉ោយប៉ែត ស្រុកម៉ាឡៃ និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាថ្ងៃទី៥ ដល់ថ្ងៃទី៦ ថ្ងៃទី៨ ដល់ថ្ងៃទី៩ ថ្ងៃទី១២ ដល់ថ្ងៃទី១៤ និងថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខសពម្ដាយបង្កើតឯកឧត្តម **ម្លែក វ៉ារី** សមាជិកក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ ស្ថិតនៅគេហដ្ឋានសព ភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលលើកទី២ ប្រចាំខែមិថុនា ឆ្នាំ២០២៣ ជាមួយយុវជន យុវនារី ទាំង៥ភូមិ ក្នុងសង្កាត់ផ្សារដើមថ្កូវ ចំនួន៥០នាក់ និងឧបត្ថម្ភថវិកាមួយចំនួន ដែលជាថវិការបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ព្រមទាំងនាំយកថវិកាមួយចំនួនជូនលោក **ជា សារុន** សមាជិកក្រុមប្រឹក្សាសង្កាត់ ដែលមានជំងឺនៅសាលាសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលយុវជន យុវនារី ខណ្ឌចំការមន នៅសកលវិទ្យាល័យបៀលធី សាខាទួលស្លែង រាជធានីភ្នំពេញ នារសៀលថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ ព្រមទាំងចែកបាយ ម្ហូប ជូនបងប្អូនប្រជាពលរដ្ឋភូមិ៤ និងភូមិ៥ នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី៦ ថ្ងៃទី១១ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីបុណ្យប្រគេនទៀនចំណាំព្រះវស្សា ចំនួន៣៩វត្ត ដើម្បីឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធ សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** និងបុព្វការីជន ព្រមទាំងញាតកាទាំងប្រាំពីរសន្តាន ក្នុងខេត្តព្រៃវែង នាព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីអបអរសាទរខួបលើកទី១៦ ទិវាអតីតយុទ្ធជន និងបំពាក់គ្រឿងឥស្សរិយយសការពារជាតិជូនអតីតយុទ្ធជន និងគ្រួសារយុទ្ធជន ស្ថិតនៅសាលប្រជុំសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំគងជ័យ ឃុំទួលសូភី និងឃុំព្រះធាតុ ស្រុកអូររាំងឪ

ខេត្តត្បូងឃ្មុំ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទាំងអស់ទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា នាថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋក្នុងភូមិសឹង ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជា-ពលរដ្ឋទាំងអស់ទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដាឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ព្រមទាំងជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំគងជ័យ ស្រុកអូររាំងឪ នារសៀលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋក្នុងភូមិថ្មដារខាង-កើត ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា នៅឃុំទួលសូភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋក្នុងភូមិទី១២ឃុំព្រះធាតុ ចំនួន២៧៥នាក់ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ព្រមទាំងជួបសំណេះសំណាលជាមួយក្រុមភ្នាក់ងារសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ និងក្រុមយុវជនស.ស.យ.ក. ទូទាំងស្រុកអូររាំងឪ ចំនួន៥២៩នាក់ នៅសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋក្នុងភូមិអំពិលតាពក ឃុំអំពិលតាពក ចំនួន១៧០នាក់ និងឃុំមៀន ចំនួន១៧០នាក់ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋជាអាជីវករក្នុងផ្សារអូររាំងឪ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

-នាថ្ងៃទី២០ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមបានអញ្ជើញជួបសំណេះសំណាលក្រុមប្រឹក្សាឃុំចេក ឃុំដំរិល និងប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

❈នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ជឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលប្រជាពលរដ្ឋដែលប្រកបរបរអ្នករត់ម៉ូតូឌុប នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់រង្វង់មូលដំរី៥០៥ សួនគោព្រៃ និងរូបព្រះភគណេស ក្រោមអធិបតីភាពឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសចូលរួមពិធីសម្ពោធអគារសិក្សាអនុវិទ្យា-ល័យ ហ៊ុន សែន អូរម្លូ ចំនួន១ខ្នង មាន៥បន្ទប់ និងទីចាត់ការចំនួន១ខ្នង ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរ-ភូមិន្ទ នៅឃុំអូរម្លូ ស្រុកស្ទឹងត្រង់ នាព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលប្រជាពលរដ្ឋចំនួន ១០.៩៧០នាក់ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋ-មន្ត្រី **យឹម ឆៃលី** ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ចាម នៅស្រុកស្ទឹងត្រង់ នាព្រឹកថ្ងៃទី២៦ ខែកក្កដា

ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យរ៉ាយ៉ាហាជ្ជី នៅខេត្តកំពត នាថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីបញ្ចុះខណ្ឌសីមាវត្តរស្មីព្រៃស្វាយ (ហៅវត្តព្រៃស្វាយ) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តរស្មីព្រៃស្វាយ ភូមិអង្គរំដួល ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។



❈នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសាលាធម្មសភានៅវត្តប្រាសាទរង្សី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅស្រុកជីក្រែង ខេត្តសៀមរាប។

❈ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅឃុំក្លាំងហាយ និងឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប នាថ្ងៃទី៧ ថ្ងៃទី៩ និងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅឃុំវ៉ារិន ឃុំល្វាក្រាំង និងឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប នាថ្ងៃទី១៥ ថ្ងៃទី១៧ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្តម **មួន ម៉យ** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅស្រុកតាវែង ខេត្តរតនគិរី នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលដ្ឋ នៅឃុំសោធំ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយលោកនាយកសាលាបឋមសិក្សាមកពីស្រុកទាំង៣ រួមមាន៖ ស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកតាំងគោក សរុបចំនួន៧៩សាលា និងលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចំនួន៣០៦នាក់ ដើម្បីមកទទួលយកសម្ភារសិក្សា ដែលជាអំណោយរបស់ឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោកនៅសាលាបឋមសិក្សាថ្មល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

-ជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយអ្នកគ្រូបង្រៀន អ្នកគ្រូពេទ្យ សរុបចំនួន២០៧នាក់ និងបានឧបត្ថម្ភ




ថវិកាមួយចំនួនដែលជារបស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលប្រជុំសាលាខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

❈នាល្ងាចថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គី ដែលរៀបចំឡើងដោយក្រសួងបរិស្ថាន នៅភោជនីយដ្ឋាន SAMBA Brazilian Steakhouse រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រគេនទៀនព្រះវស្សា និងទេយ្យទានដល់ព្រះសង្ឃគង់នៅ៣៣វត្ត ក្នុងខេត្តបាត់ដំបង ក្រោមអធិបតីភាពលោកជំទាវ **ញ៉ែម សាខន ស ខេង** នៅគេហដ្ឋានសម្ដេចក្រឡាហោម **ស ខេង** ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈ឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋសរុបចំនួន២៥០នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនសម្រាប់ធ្វើដំណើរ នៅភូមិត្រពាំងគី ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។

-នាំយកទេយ្យទានមកប្រគេនវត្តចំនួន៥គឺ វត្តមន្ទីសេដ្ឋាហៅអង្គក្តី វត្តប្រាសាទមង្គល វត្តបាណានុគ្រោះ វត្តទន្លាប់ និងវត្តសុវណ្ណារ៉ាម ក្នុងមួយវត្តៗទទួលបាន៖ ទៀនវស្សា១គូ ស្លាដក១ អង្ករ២៥គីឡូក្រាម ទឹកបរិសុទ្ធ១កេស ទឹកផ្លែឈើ១កេស ទឹកក្រូច១កេស ធូប១ដុំ ទឹកស៊ីអ៊ីវ១យួរ ទឹកត្រី១យួរ និងបច្ច័យមួយចំនួន និងជូនលោកតាអាចារ្យ១០នាក់ ក្នុងមួយនាក់ៗបានថវិកាមួយចំនួន នៅឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រជុំក្រុមប្រឹក្សាក្រុងទាំង៥ ក្រុមប្រឹក្សាស្រុកទាំង៥ ក្រុមប្រឹក្សាឃុំទំនប់ដាច់ ឃុំផ្អាវ ឃុំអូរស្វាយ ភូមិទាំង៦ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ និងឃុំបាក់អន្លូង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដើម្បីពិនិត្យផែនការការងារត្រៀមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី នាថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែមិថុនា និងថ្ងៃទី១០ ថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលបងប្អូនប្រជាពលរដ្ឋនៅភូមិអូរក្រូច ភូមិសន្តិភាព ឃុំផ្អាវ និងភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ភូមិកញ្ជៀប ឃុំគោកមន ភូមិប្រាសាទអូរទង ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល ភូមិត្បែងថ្មី ឃុំអំពិល ភូមិទំនប់ ក្នុងឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ នាថ្ងៃទី៥ ដល់ថ្ងៃទី៩ ថ្ងៃទី១២ ដល់ថ្ងៃទី១៣ និងថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

-បាននាំយកបច្ច័យមួយចំនួនទៅប្រគេនព្រះចៅអធិការ





វត្តស្រែក្រសាំង ដើម្បីរៀបចំចាក់សាប នៅសាលាឆាន់ សម្រាប់ធ្វើបុណ្យភ្ជុំបិណ្ឌនាពេលខាងមុខ នៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំទាំង៥ ប្រធានភូមិកោះធំ និងភូមិព្រៃគ្រីជើង ឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ដើម្បីពិនិត្យផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ នាថ្ងៃទី២៤ ខែមិថុនា និងថ្ងៃទី១១ ថ្ងៃទី១៣ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ប្រជុំជាមួយក្រុមប្រឹក្សាឃុំព្រៃគ្រី ដើម្បីត្រួតពិនិត្យផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ បោះឆ្នោតនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះ។ ព្រមទាំងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះក្នុងភូមិជំពារ ឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១ និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋនៅភូមិជំពារ ឃុំព្រៃគ្រី ឃុំជលសារ ឃុំពាមឆ្កោក ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៩ និងថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា១ខ្នង មានបន្ទប់ និងបំពាក់តុ កៅអីគ្រូ តុ កៅអីសិស្ស ក្តារខៀនកញ្ចក់ កង្ហារ អំពូលអគ្គិសនី និងបន្ទប់ទឹកចំនួន៣ នៅអនុវិទ្យាល័យពងទឹក ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នារសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋចំនួនពីរភូមិ ក្នុងឃុំពងទឹក ចំនួន៣.៣៧៨គ្រួសារ នៅសាលាបឋមសិក្សាចំការបី ភូមិអន្ទង់ស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ព្រមទាំងនាំយកទេយ្យទាន រួមមាន៖ អង្ករ មី ទឹកបរិសុទ្ធ ភេសជ្ជៈ និងបច្ច័យ ប្រគេនព្រះចៅអធិការវត្តឬស្សី នៅភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នារសៀលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខជាមួយប្រជាពលរដ្ឋចំនួន៥៣០នាក់ ព្រមទាំងឧបត្ថម្ភក្នុងម្នាក់ៗទទួលបាន៖ ក្រមា១ បីចេង១កញ្ចប់ និងថវិកាមួយចំនួន នៅភូមិអង្គរ និងភូមិរើលក្រោម ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៥ និងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នារសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣។

❋លោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលតំណាងគ្រូពេទ្យ គ្រូបង្រៀន និងថ្នាក់ដឹកនាំអនុសាខាសមាគមនារីខេត្តកំពង់-ចាម នៅសាលសន្និសីទសាលាខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីបញ្ចុះបឋមសិលាកសាងអគារសិក្សានៅវិទ្យាល័យ ហេង សំរិន ចក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ភូមិ និងប្រជា-ពលរដ្ឋនៅឃុំឃុនរាម ឃុំត្បែង ឃុំរំចេក និងឃុំរុនតាឯក ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ស្ថិតនៅឃុំឃុនរាម ស្រុកបន្ទាយ-ស្រី ខេត្តសៀមរាប នាព្រឹកថ្ងៃទី២ ដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ភូមិ និងប្រជា-ពលរដ្ឋនៅឃុំខ្នារសណ្ដាយ ឃុំព្រះដាក់ និងឃុំកន្ទួត ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជា-ពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ស្ថិតនៅឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប នាថ្ងៃទី៧ ថ្ងៃទី៩ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ភូមិ និងប្រជា-ពលរដ្ឋនៅឃុំតាសៀម ឃុំខ្នងភ្នំ ឃុំស្វាយលើ និងឃុំបឹងមាលា ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ស្ថិតនៅឃុំខ្នងភ្នំ ស្រុកស្វាយ-លើ ខេត្តសៀមរាប នាថ្ងៃទី១៣ ថ្ងៃទី១៥ ថ្ងៃទី១៧ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាកិត្តិយសក្នុងពិធីសំណេះសំណាល និងប្រគល់ផ្ទះចំនួន១០៧ខ្នង ដែលបានជួសជុល និងសាងសង់រួច ជូនប្រជាពលរដ្ឋក្នុងស្រុកបន្ទាយស្រី ក្រោមអធិបតីភាពដ៏ខ្ពង់-ខ្ពស់សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅស្រុកបន្ទាយស្រី ខេត្តសៀម-រាប នាព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣។

-នាំយកទៀនព្រះវស្សា ទេយ្យទាន និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោយ៍សា នៅភូមិទ្រាំង សង្កាត់ស្លក្រាម និងវត្តឥន្ទបត្តបុរីអង្គរខាងជើង នៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ភូមិ និងប្រជា-ពលរដ្ឋនៅឃុំជប់តាត្រាវ ឃុំពាក់ស្នែង ឃុំស្វាយចេក និងឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប ដើម្បីផ្សព្វផ្សាយអំពីកិច្ចការងារបោះឆ្នោត និងអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ឱ្យបានគ្រប់ៗគ្នា ព្រមទាំងឧបត្ថម្ភថវិកាដល់អាជ្ញាធរឃុំ និងប្រជា-ការពារមួយចំនួន នាថ្ងៃទី១៣ ថ្ងៃទី១៥ ថ្ងៃទី១៧ និងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❋នាព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលបងប្អូនកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។

❋នាល្ងាចថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គីជាមួយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងថ្នាក់ដឹកនាំក្រសួងបរិស្ថាន នៅភោជនីយដ្ឋាន Samba Elite Brazilian Steakhouse ខណ្ឌទួលគោក រាជធានីភ្នំពេញ។

❋នាព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធលោកជំទាវ **មិញ្ញ ភូសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាវរសិល្បការិនីរបាំព្រះរាជទ្រព្យដ៏ល្បីល្បាញនាសម័យសង្គមរាស្ត្រនិយម នៅបុរីប៉េងហួតបឹងស្នោ ផ្ទះលេខ៤៣ ផ្លូវD០៦ គម្រោង Eco Delta។



❋នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **សាយ ប៊ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាលបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៅភូមិតាម៉ុល សង្កាត់ច្បារមន ក្រុងច្បារមនខេត្តកំពង់ស្ពឺ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកកម្រងផ្កា និងបច្ច័យចូលរួមក្នុងពិធីបុណ្យសពលោកជំទាវ **មិញ្ញ ភូសនី** រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានទទួលមរណភាពដោយរោគាពាធ នៅបុរីប៉េងហួតបឹងស្នោ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាថ្ងៃរសៀលទី៥ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យគម្រប់ខួប១០ឆ្នាំ អ្នកឧកញ៉ាមហាឧបាសក **ហ៊ុន នាង** និងមហាឧបាសិកា **ឌី ប៉ុក** ដែល

ត្រូវជាឱពុកម្ដាយបង្កើតសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តជំពូកក្អែក រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមប្រជុំសភាពាណិជ្ជកម្មស្ដីពី ភាពលំបាក និងភាពងាយស្រួលរបស់អ្នកប្រកបអាជីកម្ម លើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ប្រជុំពិភាក្សាជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីស្វែងរកដំណោះស្រាយជូន និងពិធីចុះអនុស្សរណៈ នៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងនិយ័តករបរធនបាលកិច្ច នៅសភាពាណិជ្ជកម្មកម្ពុជា នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣។

-ទទួលជួបលោក Kansuke Otani ជាអតីតសមាជិកសភាប្រចាំខេត្តហ៊ីយ៉ូហ្គូ ប្រទេសជប៉ុន បច្ចុប្បន្នជាប្រធាន Japan Asia Exchage Center ដើម្បីជួបពិភាក្សាការងារស្ដីពីទំនាក់ទំនងទៅអនាគត លើផ្នែកពាណិជ្ជកម្ម ផ្នែកមនុស្សធម៌ និងជំនួយផ្សេងៗថែមទៀតទៅអនាគត នៅភោជនីយដ្ឋាន Dinak រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖



-ទទួលស្វាគមន៍ដំណើរទស្សនកិច្ចការងារមនុស្សធម៌របស់លោក Kim Jung Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣។



-ដឹកនាំកិច្ចពិភាក្សារវាងឯកឧត្តម **ពិន ប្រាកដ** អភិបាលរងខេត្តសៀមរាប ជាមួយគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយលោក Kim Jung-Nam ប្រធានមូលនិធិ ដើម្បីឈ្វេងយល់អំពីសេចក្ដីត្រូវការជំនួយមនុស្សធម៌លើវិស័យសុខាភិបាល និងអប់រំ នៅសណ្ឋាគារឡូតូសប្លង់ ព្រមទាំងទស្សនកិច្ចមន្ទីរពេទ្យគន្ធបុប្ផា ខេត្តសៀមរាបនារសៀលថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៣។



-ទស្សនាប្រាសាទអង្គរតូច ប្រាសាទតាព្រហ្ម និងប្រាសាទបាយ័ន នៅខេត្តសៀមរាប នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣។

-ជូនដំណើរលោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល និងគណៈប្រតិភូ ធ្វើមាតុភូមិនិវត្តន៍ បន្ទាប់ពីបានអញ្ជើញធ្វើទស្សនកិច្ចការងារមនុស្ស-



ធម៌ នៅព្រះរាជាណាចក្រកម្ពុជា ចំនួន៥ថ្ងៃ គឺចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២ ឯកឧត្តម **ឌុខ ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី១៦ ទិវាអតីតយុទ្ធជនកម្ពុជា ២១ ខែមិថុនា និងពិធីបំពាក់គ្រឿងឥស្សរិយសជូនអតីតយុទ្ធជនកម្ពុជា ក្រោមធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅទីក្រុងរណបកោះពេជ្រ។

❈នាល្ងាចថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារសាមគ្គី នៅភោជនីយដ្ឋាន SAMBA Brazilian Steakhouse៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឌា ជេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូចូលរួមមហាសន្និបាតលើកទី៤៨ នៃសភាប្រើភាសាបារាំង នៅទីក្រុងTBILISSI នៃសាធារណរដ្ឋ GÉORGIE៕

## ការទទួលពាក្យបណ្តឹង

❈នៅខែកក្កដា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៥ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៥ករណី បានទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន១ករណី (សល់ពីខែឧសភា ចំនួន១បណ្តឹង) ឆ្លើយតបទៅម្ចាស់បណ្តឹង (ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង) ចំនួន៥ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៥ករណី៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងឆមាសទី១ ព្រមទាំងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២៣




*ឯកឧត្តម អ៊ុំ សារិទ្ធ និងឯកឧត្តម ឡោក ឆាយ*

នាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងឆមាសទី១ ព្រមទាំងលើកទិសដៅការងារបន្តក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍នាពេលនោះ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែមិថុនា និងឆមាសទី១ ឆ្នាំ២០២៣ថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានអនុវត្តការងារសម្រេចបានលទ្ធផលកើនឡើងលើមុខងារទាំង៥ បើធៀបនឹងឆមាសទី១ ឆ្នាំ២០២២។ វឌ្ឍនភាពទាំងនេះ ជាសូចនាករ នៃការគ្រប់គ្រងដឹកនាំ និងការខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងការបំពេញការងារ អស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី ប្រកបដោយភាពធន់លើគ្រប់ការដ្ឋានការងារស្របតាមផែនការយុទ្ធសាស្ត្រ (២០២១-២០៣០) សម្រាប់ការអភិវឌ្ឍព្រឹទ្ធសភាឱ្យក្លាយជាសភាទំនើប។

ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា លទ្ធផលសម្រេចបានក្នុងឆមាសទី១ ឆ្នាំ២០២៣ តម្រូវឱ្យខិតខំបន្ថែមទៀត ដើម្បីពង្រឹងពង្រីកការងារលើគ្រប់វិស័យ និងគ្រប់មុខសញ្ញាឱ្យបានបោះជំហានទៅមុខព្រមៗគ្នា ទន្ទឹមនឹងខិតខំប្រមែប្រមូលការគាំទ្រពីសភាជាមិត្តបន្ថែមទៀតដើម្បីគាំទ្រដល់ការចាប់ផ្ដើមនីតិកាលទី៥ របស់ព្រឹទ្ធសភា។

សម្រាប់ទិសដៅខែកក្កដា និងឆមាសទី២ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំ គ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវត្រៀមសព្វសារពើសម្រាប់ការងារខាងមុខ គឺជាអាទិភាពដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ ត្រូវតែខិតខំជាអតិបរមាដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណ៍សម្បត្តិ ទាំងទីកន្លែងធ្វើការ ធនធានសម្ភារ បរិក្ខារបច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុ មានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំបានទាន់ពេលវេលា ដូចការគ្រោងទុក។ ស្របពេលជាមួយគ្នានោះ ក្នុងដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតសកល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាត្រូវផ្ដោតការយកចិត្តទុកដាក់ជាអាទិភាពក្នុងការផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបំពេញមុខងារតំណាងនៅតាមមូលដ្ឋានរៀងៗខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គឹម សិទ្ធី)



*អ្នកចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងឆមាសទី១*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមហ៊ុន Huawei រៀបចំសិក្ខាសាលាស្ដីពី ការពន្លឿនហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការបង្កើតតម្លៃថ្មីសម្រាប់សេដ្ឋកិច្ចឌីជីថល



*លោក លីង អ៊ូ និងឯកឧត្ដម អ៊ុំ សារឹទ្ធ*

នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមហ៊ុន Huawei បានរៀបចំសិក្ខាសាលាស្ដីពី ការពន្លឿនហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការបង្កើតតម្លៃថ្មីសម្រាប់សេដ្ឋកិច្ចឌីជីថល ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ថ្មីៗ ជូនដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងលោក **លីង អ៊ូ** នាយផ្នែកយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន Huawei ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការមកពីគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៧០នាក់។

មានប្រសាសន៍ក្នុងអង្គសិក្ខាសាលានាឱកាសនោះ ឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានសម្ដែងនូវការស្វាគមន៍ និងសេចក្ដីសោមនស្សរីករាយជាខ្លាំង ដែលអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រុមហ៊ុន HUAWEI ប្រចាំកម្ពុជាបានសហការរៀបចំសិក្ខាសាលានេះឡើង ពិតជាមានសារៈសំខាន់ណាស់សម្រាប់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការឈ្វេងយល់បន្ថែមពីគោលគំនិត នៃក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថល និងសន្ទស្សន៍ឌីជីថលនីយកម្មឧស្សាហកម្ម (Industrail Digitalization) ការអនុវត្តយុទ្ធសាស្ត្រឌីជីថល ការវាយតម្លៃ និងការអនុវត្តគំរូល្អៗក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅក្នុងប្រទេស។

ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ក្នុងនាមជាអង្គនីតិប្បញ្ញត្តិ ព្រឹទ្ធសភាកម្ពុជាមានឆន្ទៈ និងការប្ដេជ្ញាចិត្តប្រកបដោយការទទួលខុសត្រូវ ក្នុងការចូលរួមចំណែកកសាងសង្គមកម្ពុជា ឆ្ពោះទៅរកសង្គមសេដ្ឋកិច្ចឌីជីថលដ៏រស់រវើក ព្រមទាំងចូលរួមដោយសកម្ម និងភាព





*ទិដ្ឋភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចូលរួមក្នុងអង្គសិក្ខាសាលា*



*ទិដ្ឋភាពក្នុងអង្គសិក្ខាសាលា*

ជាដៃគូជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា គ្រប់ដំណាក់កាលឆ្ពោះទៅរកការពង្រឹង និងការកសាងខឿនសេដ្ឋកិច្ចដ៏រឹងមាំមួយក្រោមទស្សនវិស័យជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ក្នុងន័យនេះ ព្រឹទ្ធសភាកម្ពុជាបានកំណត់ចក្ខុវិស័យ និងទស្សនវិស័យក្នុងការប្រែក្លាយខ្លួនជាសភាទំនើប ដោយបានរៀបចំចងក្រងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពរបស់ព្រឹទ្ធសភា នៅក្នុងរយៈពេល១០ឆ្នាំ (២០២១-២០៣០) និងផែនការមេស្តីពី “បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិក ២០២២-២០៣០” ឱ្យស្របតាមគោលនយោបាយរាជរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

ក្នុងឱកាសនោះ លោក **លីង អ៊ូ** នាយផ្នែកយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន Huawei ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានបង្ហាញជូនអង្គសិក្ខាសាលាផ្តោតលើប្រធានបទសំខាន់ៗរួមមាន៖

**១.ឌីជីថលនីយកម្ម និងសេដ្ឋកិច្ចឌីជីថល មាន៖ ផ្លាស់ប្តូរ និន្នាការ និងតម្លៃ។**

**២.គំរូយុទ្ធសាស្ត្រឌីជីថលជាតិ មាន៖ក្របខ័ណ្ឌ ធាតុសំខាន់ គំរូ និងករណី។**

**៣.ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគឺជាមូលដ្ឋានគ្រឹះ មាន៖ ការកសាង ការអភិវឌ្ឍ និងនវានុវត្តន៍៕**

( អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)





*ឯកឧត្តម អ៊ុំ សារិទ្ធ ប្រគល់វត្ថុអនុស្សាវរីយ៍ជូនលោក លីង អ៊ូ និងថតរូបអនុស្សាវរីយ*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❋នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❋នារសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូខេត្តហុកកៀន នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយលោក Liu linshuang ទីប្រឹក្សារដ្ឋបាលក្រុងឈានចូវ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី៦ ទី១៩ និងទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចជុំត្រួតពិនិត្យពិភាក្សាលើការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំង៥ និងប្រធានអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល ឆ្នាំ ២០២៤-២០២៦ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យលើគម្រោងថវិកាឆ្នាំ២០២៤ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ












❈នារសៀលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ គណៈកម្មការគ្រប់គ្រងដំណើរការវាយតម្លៃបន្តកិច្ចសន្យាដល់បុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពឯកឧត្ដម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេចលើព្រឹត្តិបត្រវាយតម្លៃបន្តកិច្ចសន្យាការងាររបស់បុគ្គលិកជាប់កិច្ចសន្យា នៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបញ្ហាផ្សេងៗ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។

❈នារសៀលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញផ្ដល់កិត្តិយសធ្វើបាឋកថាស្ដីពី កិច្ចការសភាកាណាដា ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

❈នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្ដម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំគណៈប្រតិភូនៃក្រុមអ្នកនយោបាយអាយ (AIPA) ដើម្បីត្រៀមចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ នៃក្រុមអ្នកនយោបាយនៃអន្តរសភាអាស៊ានលើកទី១៤ នៅសាលប្រជុំពិសេសកណ្ដាល វិមានព្រឹទ្ធសភា។

❈នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្ដម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូសភាកម្ពុជា ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយនៃអន្តរសភាអាស៊ានលើកទី១៤ នៅខេត្ត Kien Giang សាធារណរដ្ឋសង្គមនិយមវៀតណាម។

❈ពីថ្ងៃទី២៦ ដល់ទី៣០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ុន ឧុទ្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី "ទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវសភា៖ ការពង្រឹងស្ថាប័ន" នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ




❈នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ុន ឫទ្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសម្ហហភាពដែនដី បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសម្ហហភាពដែនដី ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៣ ព្រមទាំងលើកទិសដៅការងារបន្ត នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារសិក្សាស្រាវជ្រាវស្តីពីគោលការណ៍ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធនឹងផលប្រយោជន៍មន្ត្រីរាជការ ដឹកនាំដោយឯកឧត្តម **ទេព ចាន់អុនឧុធីរក្ស** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំអគារក្រហមស្លាបខាងកើត វិមានព្រឹទ្ធសភា។



❈ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូខេត្តហុកកៀន នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយលោក Liu linshuang ទីប្រឹក្សារដ្ឋបាលក្រុងឈានចូវ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។



❈ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញជូនដំណើរមាតុភូមិនិវត្តន៍គណៈប្រតិភូខេត្តហុកកៀន នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយលោក Liu linshuang ទីប្រឹក្សារដ្ឋបាលក្រុងឈានចូវ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។



❈នាល្ងាចថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកសាររំលែកទុក្ខ និងបច្ច័យរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព និងគោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ម៉ិញ កុសនី** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅបុរីប៉េងហួតបឹងស្នោ ផ្ទះលេខ៤៣ ផ្លូវD០៦៕

